# ១២ ប្រការប្រមុខនៃក្តីវិនាស

នៅក្នុងគម្ពីរសុត្តន្តបិដក, ខុទ្ទកនិកាយ, សត្តនិបាត, តតិយភាគទី៥៩, ទំព័រទី៣៦ (បរា ភវសូត្រ ) មានដំណាលថា បន្ទាប់ពីបានស្តាប់នូវការបកស្រាយរបស់ព្រះសម្មាសម្ពុទ្ធអំពីហេតុដែលនាំមកនូវក្តីចំរើន ឬ មង្គល (មង្គលសូត្រ ៣៨ប្រការ) រួចហើយ ពួកមនុស្ស និង ទេវតាទាំងឡាយដែលធ្លាប់តែមានការខ្វែងគំនិតគ្នានោះ ក៏បានស្រុះស្រួលស្រស់ស្រាយនឹងគ្នាឡើងដោយពុំមានក្តីមន្ទឹលឡើយ ។ មិនយូរប៉ុន្មាន ពួកគេមានគំនិតមួយកើតឡើងថា ធម្មតាក្នុងលោកនេះរមែងមានសភាវៈជាគូនឹងគ្នា គឺថា៖ មាន គូនឹង ក្រ, សុខ គូនឹង ទុក្ខ ជាដើម, ហេតុនេះ ហេតុនៃក្តីចំរើនត្រូវតែជាគូនឹងហេតុនៃក្តីវិនាស ។ ព្រះសមណគោត្តមបានដឹងនូវហេតុនៃក្តីចំរើន ដូចដែលព្រះអង្គបានសំដែងប្រាប់យើងរួចហើយ ហើយជាធម៌ដ៏ពិរោះដែលពួកយើងពុំធ្លាប់បានឮ ហេតុនេះព្រះអង្គពិតជាដឹងអំពីហេតុ នៃ ក្តីវិនាស ។ ហេតុនេះទើបពួកគេបានមូលគំនិតគ្នាទៅទូលសួរព្រះពុទ្ធថា៖ “បពិត ព្រះសមណគោត្តមបរមសាស្តាដ៏ចំរើន សូមព្រះអង្គមេត្តាប្រាប់ពួកយើងខ្ញុំអោយបានដឹងនូវហេតុ ដែលនាំអោយមនុស្សសត្វក្នុងលោកសន្និវាសនេះនឹងជួបនូវ ក្តីវិនាសសាបសូន្យចាកគុណដោយប្រការយ៉ាងណា?” ។

ព្រះពុទ្ធបានសំដែងថាហេតុនៃក្តីវិនាសមានដូចតទៅ:

១- បុគ្គលអ្នកទ្រូស្តធម៌, ស្អប់ធម៌

ធម៌ សំដៅដល់ការបង្រៀន ឬ គោលការណ៍ទាំងឡាយណាដែលត្រឹមត្រូវទៅតាមសភាវៈពិត ពុំមែនជាការក្លែងបន្លំ, ល្បួងលួងលោម, បញ្ឆោតបញ្ចុះបញ្ចូល ។ ធម៌ក៏បានដល់ការបង្រៀនទាំឡាយរបស់ព្រះសម្មាសម្ពុទ្ធផងដែរ ព្រោះព្រះពុទ្ធបង្រៀនតែអ្វីដែលពិត (ចូរប្រយ័ត្នច្រឡំគ្នារវាងការបង្រៀនរបស់ព្រះពុទ្ធ និង ទស្សនៈមួយចំនួនដែល ពុទ្ធសាសនិកបានតាក់តែងឡើងដូចជាធម៌ដែលយើងធ្លាប់ឮព្រះសង្ឃ និង ពុទ្ធបរិស័ទសូត្រនៅពេលបុណ្យទានជាដើម ។ ធម៌របស់ព្រះពុទ្ធ មិនមែនមានន័យថា ធម៌សម្រាប់សូត្រឡើយ ។ ប៉ុន្តែក៏មានធម៌ដែលជាការបង្រៀនរបស់ព្រះពុទ្ធ ត្រូវបានគេសូត្រដែរ, ដូចជាធម៌ពហុទេវា គឺមង្គលសូត្រ និង ធម្មចក្កប្បវត្តនសូត្រ ជាដើម) ។ ន័យម្យ៉ាងទៀតថា ធម៌ = សភាវៈពិត ។ ហេតុនេះបុគ្គលអ្នកទ្រូស្តធម៌ ស្អប់ធម៌ គឺបុគ្គលទ្រូស្ត និង ស្អប់នូវមុខវិជ្ជាពិត មុខវិជ្ជាមិនកុហក ហើយចូលចិត្តតែ

ការបង្រៀនឬទ្រឹស្តីទាំងឡាយណាដែលជាការកុហក, លួងលោម, បញ្ឆោត បំភាន់បន្លំ ។

ប្រការនេះ នឹងនាំមកនូវក្តីវិនាសជាច្រើន ក្នុងនោះវិនាសដំបូងបំផុតដែលខ្លួនគេមិនដឹងគឺវិនាសបញ្ញា គឺគេមិនដឹងការពិត ដោយហេតុតែគេស្អប់ការពិត មិនព្យាយាមស្វះស្វែង ខ្នះខ្នែងឈ្វេងយល់ សង្កេតពិនិត្យ គិតពិចារណា សិក្សា អោយបានដឹងការពិត ដោយហេតុតែគេមិនចូលចិត្តអ្វីដែលពិត ចូលចិត្ត និង លុះតែក្នុងការបំភាន់គំនិតប្រាជ្ញា ។ ហេតុនេះ ចាប់ពីពេលនោះទៅ គេបានចេះ និង បានដឹង និង សិក្សាតែក្នុងរឿងមិនត្រឹម មិនត្រូវ ហើយការប្រព្រឹត្តិរបស់គេ ទាំងពាក្យសំដី ទាំងទង្វើក៏សុទ្ធតែប្រព្រឹត្តក្នុងនិយាមខុសពីការពិតទាំងអស់ ហើយលទ្ធផលក៏ស្របតាមអ្វីដែលគេធ្វើនោះឯង ។ ដូច្នេះ ការទ្រូស្តធម៌ និង ស្អប់ធម៌ ជាប្រមុខនៃក្តីវិនាសទី១ ។

## ២- បុគ្គលស្រលាញ់ពេញចិត្ត និង សេពគប់នឹងជនជាអសប្បុរស មានកិរិយាមិនសេពគប់នឹង ជនជាសប្បុរស

ជនជាអសប្បុរសមានន័យស្មើនឹងបុគ្គលពាលដែរហើយមានគ្រឿងសំគាល់គឺ

ក. បុគ្គលលង់ខ្លៅ គ្មានគំនិតប្រាជ្ញា ហើយមិនគិតកសាងសមត្ថភាព និង គំនិតប្រាជ្ញា ជាបុគ្គលរីករាយក្នុងភាពលង់ខ្លៅ មិនស្តាប់ដំបូន្មានលោកអ្នកប្រាជ្ញ ឬចាស់ព្រឹទ្ធាចារ្យ ចាត់ទុកជាបុគ្គលពាលជំពូកមួយ ដោយហេតុធ្វើខ្លួនអោយជាបុគ្គលមិនមានប្រយោជន៍ ឬធ្វើខ្លួនអោយបាត់បង់ឱកាសក្នុងការសាងគុណតម្លៃក្នុងពេលដែលខ្លួន មានឱកាសកើតជាមនុស្ស ។

ខ. បុគ្គលស្វែងរកក្តីសុខ ឬ ប្រយោជន៍ខ្លួនឯង ដោយការធ្វើអោយខូចប្រយោជន៍អ្នកដទៃខូចក្តីសុខអ្នកដទៃ

គ. បុគ្គលធ្វើអោយខូចប្រយោជន៍អ្នកដទៃផង ខ្លួនឯងផង

នៅក្នុងមង្គលសូត្រ ព្រះពុទ្ធបង្រៀនថា ការសេពគប់ត្រូវតែធ្វើឡើងដោយបញ្ញា ត្បិតថា បើសេពគប់ជាមួយមនុស្សប្រភេទណា យើងនឹងក្លាយជាមនុស្សប្រភេទនោះដែរទោះតិច ឬ ច្រើនមិនលែងឡើយ ។ បុគ្គលពាលទាំង៣ ជំពូកខាងលើ ជាប្រភេទមនុស្សគួរអោយខ្លាចជាងអ្វីៗទាំងអស់ ហើយមិនគប្បីសេពគប់ជាដាច់ខាត ព្រោះការសេពគប់ជាមួយបុគ្គលប្រភេទនេះ ផ្សេងពីធ្វើអោយយើងវិនាសប្រយោជន៍ អាសោចិកេរ្តិ៍ឈ្មោះ អស់ទ្រព្យសម្បត្តិ ខាតពេលវេលា គំនិតប្រាជ្ញាទៅ ថែមទាំងនាំអោយយើងក្លាយជាបុគ្គលពាលជាមួយគេផងទៀត ។ ព្រះពុទ្ធ

បានបង្រៀនថា ប្រសិនបើក្នុងលោកនេះ មានតែមនុស្សពីរនាក់ គឺម្នាក់ជារូបយើង ហើយម្នាក់ទៀតជាបុគ្គលពាលក្តី ក៏មិនគប្បីទៅសេពគប់បុគ្គលនោះឡើយ ហើយគប្បីនៅតែម្នាក់ឯងដោយរឹងមាំចុះ ។

ចំណែកជនជាសប្បុរសបានដល់បុគ្គលទាំងឡាយណាដែលជាអ្នកមាន ចំណេះវិជ្ជាខ្ពង់ខ្ពស់ មានគុណធម៌ មានគំនិតប្រាជ្ញា មិនបៀតបៀនអោយខូចប្រយោជន៍គេក្តី ឈ្មោះខ្លួនឯងផង មិនបៀតបៀនក្តីសុខអ្នកដទៃផង ធ្វើតែអំពើជាប្រយោជន៍ដល់ខ្លួនឯងផង ធ្វើតែកិច្ចការជាប្រយោជន៍រួមផង ។ បុគ្គលណាសេពគប់នឹងលោកអ្នកជាសប្បុរសទាំងនេះ រមែងមិនសាបសូន្យ មិនមានទោស ហើយលោកតែងដឹកនាំអោយយើងដើរទៅរកក្តីចំរើនជានិរន្តរ៍ទៀតផង ។ បុគ្គលដែលមិនបានសេពគប់នឹងលោកជាអ្នកសប្បុរសបែបនេះ បុគ្គលនោះពេញជាខាតបង់យ៉ាងធំធេងក្នុងជីវិត ព្រោះមិនបានចាប់យកឱកាសទាំងប្រយោជន៍ទ្រព្យសម្បត្តិ ទាំងគំនិតប្រាជ្ញា និង ភ័ព្វសំណាងផ្សេងៗ ។ ហេតុនេះបុគ្គលអ្នកចូលចិត្តសេពគប់ នឹងជនជាអប្បុរស មានកិរិយាមិនសេពគប់នឹងជនជាសប្បុរស ជាប្រមុខនៃក្តីវិនាសទី២ ។

### ៣- អ្នកដេកច្រើន១, អ្នកនិយាយច្រើន១, អ្នកខ្ជិលច្រអូស១, ពេលខឹងសំដែងអោយគេឃើញបាន១

ដេកច្រើនពេក ខាតពេលក្នុងការប្រកបការងារ សិក្សារៀនសូត្រ បណ្តាលអោយស្ពឹកដៃជើង ស្ពក់ខួរក្បាល អ័ព្ទគំនិត ស្និតក្រៀមប្រាជ្ញា ប្រាថ្នានឹងគិតអ្វីក៏ពុំផ្លុះធ្លាយ ទោរទន់ទៅរកតែក្តីងោកងុយ លុះពេលក្រោកពីដំណេកកាលណាក៏ប្រាថ្នា នឹកឃើញតែបរិភោគ រួចក៏ងោកងុយទៀត ។

ប្រសិនបើធម្មជាតិអនុគ្រោះអោយមនុស្សនិយាយច្រើនជាងស្តាប់ និង ច្រើនជាងមើលនោះ ធម្មជាតិមុខជាបានបង្កើតអោយមនុស្សមានមាត់ពីរ ឯត្រចៀកតែមួយ និង ភ្នែកតែមួយដែរហើយ ។ និយាយច្រើនពេក រមែងមានការភ្លាំងភ្លាត់ ប្រាសចាកសិល្ប: នាំអោយការនិយាយក្លាយជាពោយពាយឥតខ្លឹមសារ ។ និយាយរឹតតែច្រើនទំលាយ អាថិកំបាំងកាន់តែច្រើន បង្ហាញអោយគេឃើញចំណុចខ្សោយកាន់តែច្រើន ។ អ្នកស្តាប់កាន់តែធុញថប់ អ្នកដទៃមិនបាននិយាយ ធ្វើអោយខ្លួនឯងបាត់បង់ឱកាសស្តាប់គំនិតរបស់ដៃគូ ធ្វើអោយបាត់បង់ព័ត៌មានពីដៃគូ ខានសិក្សាពីអ្នកដទៃ ខាតប្រាជ្ញា ។

មិនថាបុគ្គលណាជឿព្រះ ឬ មិនជឿព្រះឡើយ ប៉ុន្តែគ្រប់គ្នាបានទទួលអ្វីមួយសុទ្ធតែបានមកដោយការប្រកបការងារ មិនដែលបានមកដោយព្រះ ឬអាទិទេពយកមកអោយឡើយ ហើយបើគេធ្វើការដោយត្រឹមត្រូវនោះ ទោះជាគេបួងសួងព្រះក្តី មិនបួង សួងព្រះក្តី ក៏សុទ្ធតែបានផលដូចគ្នា ។ ព្រះពុទ្ធបានសំដែងថា តថាគតមិនដែលបង្រៀនថា អោយអ្នករង់ចាំព្រេងសំណាងឡើយ ប៉ុន្តែតថាគតតែងតែបង្រៀនអ្នកអោយធ្វើការដើម្បីទទួលបានផលសំណាង[១] ។ ព្រះពុទ្ធសាសនាជឿថាមនុស្សមានព្រេងសំណាងពីអតីតជាតិ ប៉ុន្តែ បានអះអាងថា ព្រេងសំណាងគឺអ្វី ដែលគេធ្វើហើយពីពេលខាងដើមនោះ ប្រៀបដូចជាកំណប់ដែលគេកប់នៅក្នុងដី ដែលគេត្រូវតែធ្វើការ គឺតោងតែជីកកកាយ យកចេញពីក្នុងដី ប្រកបដោយក្តីព្យាយាមយ៉ាងមាំ ប្រាសចាកក្តីរាយមាយ ទើបអាចរកកំណប់នោះឃើញ បើពុំនោះទេកំណប់នោះនឹងនៅក្នុងដីជារៀងរហូត ។ ហេតុនេះ បុគ្គលណាមិនធ្វើការ ឬ ធ្វើមិនមានក្តីព្យាយាមអោយបានពេញលេញទេ បើទោះបីខ្លួនគេជាមនុស្សមានភ័ព្វក្តី ក៏គេក្លាយទៅជាមនុស្សឥតភ័ព្វទៅវិញ ។ ផ្ទុយទៅវិញបុគ្គលណា ពុំមានព្រេងសំណាងក្តី បើគេខិតខំធ្វើការមិនខ្ជិលច្រអូស យកចិត្តទុកដាក់ពិនិត្យ ពិចារណារកវិធី រហូតឃើញឧបាយដ៏ត្រូវនោះ គេក៏អាចរកទ្រព្យបានដែរ ដូចពុទ្ធភាសិតថា បុគ្គលឆ្លងអន្លង់ទុក្ខ (និងឧបសគ្គគ្រប់ប្រការ ដោយរួមទាំងភាពលង់ខ្លៅ ភាពក្រខ្សត់ ។ល។ ) បានដោយក្តីព្យាយាម ។ កាលណាមានភាពខ្ជិលច្រអូសហើយ ប្រយោជន៍ទាំងឡាយ មានការស្វែងរកទ្រព្យសម្បត្តិក្តី កិត្តិយសក្តី ស្វែងរកចំណេះវិជ្ជាក្តី ទោះជាជននោះអធិដ្ឋានចំពោះព្រះ ឬអាទិទេពណាក៏គេមិនបានសម្រេចអ្វីឡើយ ។ បើពោលដល់ការស្វែងរកធម៌ជាន់ខ្ពស់ ដើម្បីសម្រេចមគ្គផល និព្វាន ទៀតនោះរឹតតែមិនបានសម្រេចសោះតែម្តង ត្បិតធម៌ទាំងនោះត្រូវការនូវក្តីព្យាយាមយ៉ាងខ្លាំង ទាំងការហាត់ពត់ផ្លូវកាយ និង ផ្លូវចិត្តអោយដល់ថ្នាក់ឯក ។

ខឹងសំដែងអោយគេឃើញបាន គឺបញ្ចេញអាកប្បកិរិយាអោយអ្នកដទៃដឹង ឬ មើលយល់បានថាយើងខឹង ឬ ត្រូវបានកំហឹងគ្របដណ្តប់ហើយ ។ បុថុជ្ជន គឺជនដែលនៅក្រាសដោយកិលេស រមែងមានការញាប់ញ័រ គឺសប្បាយ រីករាយ រំភើប ពោលគឺសោមនស្ស និងទោមនស្សចំពោះលោកធម៌៨យ៉ាងគឺមានៈលាភសក្ការៈ១, ការបាត់ បង់យសស័ក្តិ១, ការបាននូវការសរសើរ១, ការបានសុខសប្បាយ១, ការបាត់បង់លាភ សក្ការៈ១, ការបាត់បង់យសស័ក្តិ

១, ការបាននូវការនិន្ទារិះគន់១, ការបាននូវទុក្ខទោស១ ។ មួយសោតក្នុងជីវិតប្រចាំថ្ងៃ មនុស្សគ្រប់រូបតែប៉ះទង្គិចនឹងរឿងមិនជាទីពេញចិត្តក៏ច្រើន ដូចជារងនូវការតិះដៀល ឬ និយាយបង្អាច់បង្អួច ឬ ត្រូវគេបៀតបៀនជាដើម ។ ជាទូទៅបុគ្គលដែល មានការអប់រំចិត្តតិចតួច ឬ ជាអ្នកមិនមានការគ្រប់គ្រង់អារម្មណ៍ អោយបានល្អនោះរមែងប្រតិកម្មតាមសភាវគតិ នៃកំហឹង ( កំហឹងទល់កំហល់) ។

ប្រការនេះធ្វើអោយអ្នកដទៃ ជាពិសេសគូសត្រូវងាយនឹងមើលចំណុចខ្សោយរបស់យើង ហើយងាយនឹងរុញច្រាន ឬអូសទាញយើងអោយធ្លាក់ទៅក្នុងរណ្ដៅអន្តរាយផ្សេងៗ ។ ចំពោះអ្នកដទៃ នឹងមើលមកយើងថា ជាប្រភេទមនុស្សពុំមានក្តីអត់ធ្មត់ ជាមនុស្សចិត្តស្រាល ។ ជនជាសប្បុរស និង បណ្ឌិតទាំងឡាយ លោករមែងមិនសេពគប់នឹងបុគ្គលគ្មានខន្តីខ្ជាប់ខ្ជួនឡើយ ដែលការណ៍នេះធ្វើអោយយើងក្រៅពីងាយត្រូវសត្រូវធ្វើបាបទៅ នៅបាត់បង់ឱកាសនៃការអនុគ្រោះ ពីលោកអ្នកសប្បុរស និង បណ្ឌិតទាំងឡាយ បាត់បង់ឱកាសទទួលបានប្រយោជន៍ពីពួកលោកទាំងនោះ បែរជាបានតែឱកាសវាយប្រហារយ៉ាងផុយស្រួយពីអមិត្តទៅវិញ ។ បុគ្គលប្រភេទនេះ ជាដំបូងគឺវិនាសក្តីអត់ធ្មត់ បន្ទាប់មកបាត់បង់គ្រឿងលំអ គឺភាពថ្លៃថ្នូរ ធ្វើអោយអ្នកដទៃ ក្រែងរអា និង ងាយត្រូវគេបញ្ឆោះ ។ ទោះខឹងប៉ុណ្ណា ធ្ងន់ធ្ងរប៉ុណ្ណាក្តី ជនជាបណ្ឌិត តែងតែប្រព្រឹត្តខ្លួនប្រតិកម្មចំពោះបញ្ហាទាំងឡាយ ក្នុងសភាពស្ងប់ស្ងាត់ ទន់ភ្លន់ ប៉ុន្តែមានសភាពស្វាហាប់ ម៉ឺងម៉ាត់ រឹងមាំ និង មានទំងន់ដូចថ្មភ្នំដែលមិនកក្រើកដោយកំលាំងព្យុះ ហើយក៏មិនញាប់ញ័រដោយអគ្គិភ័យ ។

ហេតុនេះ អ្នកដេកច្រើន១, អ្នកនិយាយច្រើន១, អ្នកខ្ជិលច្រអូស១, អ្នកណាពេលខឹងសំដែងអោយគេឃើញបាន១ ជាប្រមុខនៃក្តីវិនាសទី ៣ ។

### ៤- បុគ្គលអ្នកមានទ្រព្យធនធានច្រើន ប៉ុន្តែមិនបានចិញ្ចឹមមាតាបិតាដោយសមគួរ

សត្វសេកស៊ីផ្លែជ្រៃហើយ ហោះហើរទៅបាត់ដោយមិនបានអរគុណ ដឹងគុណ ឬ មិនទាំងងាកក្រោយមើលដើមជ្រៃផង ក៏មិនទទួលបានការតិះដៀលអ្វីដែរ ព្រោះសត្វគ្មានវិចារណញ្ញាណ មិនចេះគិតគុណទោសអ្វីឡើយ ។ ប៉ុន្តែ សម្រាប់មនុស្សដែលមានទ្រព្យសម្បត្តិហើយ សូម្បីតែឪពុក ម្តាយរបស់ខ្លួន ជាអ្នកមានគុណ ក៏គេមិនទាំងអើពើ ហើយក៏អាចមើលរំលងទៅកើតនោះ តើសង្ឃឹមថានឹងមានគុណធម៌ ឬ សេចក្តីល្អ កើតចេញពីបុគ្គល

ប្រភេទនេះយ៉ាងម្ដេចនឹងបានទៅ ។

តាមពិត,កូនត្រូវធ្វើចំពោះឪពុកម្ដាយដោយប្រការ៥យ៉ាងគឺ ត្រូវចិញ្ចឹម មាតា បិតា១,ធ្វើការងារជំនួសគាត់១,រក្សាវង្សត្រកូលឱ្យគង់វង្ស និងខ្ពង់ខ្ពស់១(ដោយការមិនប្រព្រឹត្តិអោយថោកទាបដល់វង្សត្រកូល និង លើកតំកើងត្រកូល) , ធ្វើខ្លួនឱ្យសមរម្យជាអ្នក ទទួលមរតកពីគាត់១, និង ធ្វើបុណ្យជូនគាត់ពេលពួកគាត់លាចាកលោកនេះ១ ។

ពេល មាតាបិតា លាចាកលោកទៅហើយ មិនអើពើជារឿងមួយ ប៉ុន្តែ ពេលពួកគាត់នៅរស់ហើយខ្លួនមិនអើពើនោះ តើអោយសប្បុរស និង បណ្ឌិតទាំងឡាយផ្ដល់ទំនុកចិត្ត អោយតម្លៃបុគ្គលនោះយ៉ាងណាទៅ ? សូម្បីតែមនុស្សធម្មតា ក៏រមែងតិះដៀលបុគ្គលដែលមានធនធានហើយមិនបានផ្គត់ផ្គង់ឪពុក ម្ដាយ បណ្ដោយអោយពួកគាត់រងទុក្ខ វេទនា ដោយក្ដីស្រេក ឃ្លាន និង រងាជាដើមនោះដែរ ។ បុគ្គលនេះវិនាសជាដំបូងគឺ គុណតម្លៃ បន្ទាប់មកនឹងបាត់បង់ទំនុកចិត្តពីកល្យាណជន ។ គេច្រើនឃើញថា លុះបុគ្គលប្រភេទនេះមានកូនទៅ ក៏កូននោះពុំសូវប្រែកបដោយធម៌ឡើយ ព្រោះកូននោះដើរតាមគន្លងឪពុកម្ដាយ ប៉ុន្តែបើបែរជាមានសំណាងមានកូនចេះដឹងខុសត្រូវវិញ រមែងឃើញឪពុកម្ដាយខ្លួនថាជាបុគ្គលអធម៌ ក៏រមែងលួចតិះដៀលក្នុងចិត្ត ដែលប្រការនេះ ធ្វើអោយកូនល្អនោះមានទោសដែរ ។ ហេតុនេះ បុគ្គលអ្នកមានទ្រព្យធនធានច្រើន ប៉ុន្តែមិនបានចិញ្ចឹមមាតាបិតា ដោយសមគួរ ជាប្រមុខនៃក្ដីវិនាសទី ៤ ។

### ៥- បុគ្គលអ្នកភូតកុហក បោកបញ្ឆោតពួកសមណ: ព្រាហ្មណ៍ ស្មូម ឬ អ្នកដទៃ

សមណ: (អ្នកស្ងប់ ) ឬ ជី ឬ ព្រាហ្មណ៍ គឺសំដៅដល់ពួកបព្វជិតក្នុងសាសនាទាំង ឡាយ ។ ក៏ដូចជាពួកស្មូមទាំងឡាយដែរ ពួកបព្វជិតទាំងនេះ រស់នៅដោសារការ បរិច្ចាគទានពីអ្នកមានមេត្តា និង ជ្រះថ្លា ។ ជនកំហូចខ្លះ ឃើញពួកអ្នកបួសមានព្រះ សង្ឃជាដើម ក៏ពោលឡើងថា លោកម្ចាស់ ! នៅទីនោះ គ្រួសារនោះ គេមានរៀបចំធ្វើទាន ចំពោះលោកអ្នកមានសីល និង ចំពោះពួកស្មូមទាំងឡាយ..... សូមលោកម្ចាស់និមន្តទៅត្រកូលនោះ ទីនោះចុះ ដើម្បីធ្វើសេចក្ដីអនុគ្រោះដល់សត្វលោកដែលមានសេចក្ដីជ្រះថ្លាផង និង ដើម្បីលោកម្ចាស់បាននូវគ្រឿងអាស្រ័យទាំងឡាយ មានអាហារជាដើមផង....។ លុះពេលលោកនិមន្តទៅ ទើបឃើញថា ជាការកុហកជាក់ស្បាន់ ធ្វើអោយលោកខាតពេលជាច្រើន....។ មិនទាន់គិតដល់បាបកម្មជាតិខាងមុខទេ យើងគិតត្រឹមតែបច្ចុប្បន្នជាតិនេះ ក៏ឃើញថាទារុណ ណាស់ទៅហើយ ។

អ្នកដទៃនឹងមើលទៅបុគ្គលនោះថា ជាមនុស្សគ្មានគុណធម៌ គ្មានគារវធម៌គឺការគោរព បន្តិចបន្តួច ក្នុងខ្លួនទាល់តែសោះ ជាមនុស្សមិនអាចទុកចិត្តបាន ត្បិតសូម្បីតែពួកបព្វជិតជាអ្នករក្សាសីល ពួកស្ងួមជាអ្នកខ្សត់ខ្សោយដល់ម្លឹងហើយ ក៏គេមិនយល់មុខផង ចុះទម្រាំបើមនុស្សធម្មតា តើនឹងទទួលបានភាពសុចរិតពីមនុស្សនេះដោយប្រការណាទៅ ?

ការកុហកដោយបំណងធ្វើបាប ធ្វើអោយគេខូចប្រយោជន៍ ខូចកិត្តិយស បែកបាក់សាមគ្គី ពោលគឺកុហក ក្នុងបំណងទុច្ចរិតក្តី ក្នុងបំណងលេងសើចក្តី រមែងអោយអ្នក ដទៃស្អប់ខ្ពើម ក្តៅក្រហាយ ហើយនឹងអាចញ៉ាំងអន្តរាយ មកវិញជាការផ្ទាញ់ផ្ទាលក៏សឹងមាន ។ម្យ៉ាងទៀត អ្នកពោលពាក្យកហុក នឹងធ្វើអោយអ្នកដទៃបាត់បង់ទំនុក ចិត្ត អស់ភាពជឿជាក់ ។ មនុស្សគេតែងយកសំដី គឺការគោរពពាក្យសំដី បើពាក្យសំដីយកជាការលែងបានទៅហើយ តើរំពឹងលើអ្វី ? ហេតុនេះ ការកុហកជាប្រមុខនៃក្តីវិនាសទី៥ ។

### ៦- អ្នកមានធនធាន និង អាហារឆ្ងាញ់ពិសារ លាក់ទុកតែម្នាក់ឯង

មនុស្សក្នុងលោករមែងមានការពឹងអាស្រ័យគ្នាទៅវិញទៅមកដោយប្រការ ណាមួយ ។ បុគ្គលណារត់ទៅរកគេ ពោលពាក្យផ្អែមពីរោះ តែពេលត្រូវការគេ ឬ ពេលមានទុក្ខ លុះពេលគេត្រូវការវិញ ក៏គេចមុខបាត់ ដោយសំអាងលេសថា មានធុរៈនេះ ធុរៈនោះ ឬ មិនអើពើ មិនខ្វះខ្វែងជួយគេវិញ ដោយប្រការមួយ ។ ពេលខ្លួនអត់ឃ្លាន រត់រកគេ លុះពេលបានសុខ ឬ ពេលមានរបស់ប្រណីត មានអាហារឆាញ់ពិសារ ក៏សំងំលាក់ខ្លួនពួនសោយសុខតែម្នាក់ឯង ( បុគ្គលខ្លះពេលសោយសុខរួចហើយ ក៏ទើបទៅអួតអាងប្រាប់គេទៀត ) មិនចែករំលែកអ្នកដទៃដោយប្រការមួយ ។ លុះពេលត្រូវការពឹងអាស្រ័យគេនៅគ្រាក្រោយទៀតនោះ តើបុគ្គលណាទៅហ្ន ដែលមានចិត្តនៅជួយបុគ្គលប្រភេទនេះទៀតនោះ ! ហេតុនេះបុគ្គលអ្នកមានធនធាន និង អាហារឆ្ងាញ់ពិសារហើយក្រសោបទុកតែម្នាក់ឯង ជាប្រមុខនៃក្តីវិនាសទី៦ ។

### ៧- បុគ្គលអ្នកប្រកាន់រើសអើងជាតិសាសន៍ ត្រកូល ទ្រព្យសម្បត្តិ ឋានៈ ហើយមើលងាយអ្នកដទៃ មើលស្រាលញាតិសន្តាន មិនប្រមូលញាតិមិត្ត

សត្វលាដឹកលាមក ក៏ស៊ីស្មៅ សត្វលាដឹកមាសក៏ស៊ីស្មៅ ។ ជីវិតលើលោកនេះ មាន តម្លៃស្មើគ្នា រឿងឋានៈ ជាតិសាសន៍ ត្រកូល ទ្រព្យសម្បត្តិ រួមទាំងរបស់ជាច្រើនទៀតនៅក្នុងលោកនេះ រមែងមានភាពខុសគ្នាជាធម្មតា ដែលមិនគប្បីយករបស់ទាំងនោះជាកត្តាវាស់វែងមនុស្ស

ឡើយ ។ ការប្រព្រឹត្តិលើកកំពស់ខ្លួនឯង ហើយមិនគោរ ពអ្នកដទៃ មើលងាយអ្នកដទៃ សូម្បីសាច់ញាតិខ្លួនឯងក៏មិនអើពើផង ដោយហេតុតែគិតថា គេក្រ តូចទាប អន់ថយជាងខ្លួនជាដើម នោះ រមែងធ្វើអោយខ្លួនឯងជាមនុស្សឯកោ លែងមាន របងការពារ ហើយអាចធ្វើអោយអ្នកខ្លះក្តៅក្រហាយ ស្អប់ខ្ពើម និង ជាគោលដៅនៃការចងគំនុំ ក៏សឹងមាន ។ ហេតុនេះ ការប្រកាន់ខ្លួន មើលងាយអ្នកដទៃ មិនប្រមូលញាតិ និង មិត្ត ជាប្រមុខនៃក្តីវិនាសទី៧ ។

## ៨- ជនអ្នកប្រព្រឹត្តល្បែង៣ប្រការ គឺល្បែងស្រី១ ល្បែងស្រា១ និង ល្បែងភ្នាល់ទាំងឡាយ១

ត្រេកអរចំពោះភរិយាខ្លួនជាការប្រពៃ ប៉ុន្តែការលេងល្បែងស្រីរមែងជួបផលអវិជ្ជ មានជាច្រើនដូចជា ខូចខាតទ្រព្យដែលមានស្រាប់ ខានបានរកទ្រព្យថ្មី មានបញ្ហាទាស់ទែងគ្នាជារឿយៗ ដើរលេងចោលទ្រព្យសម្បត្តិ ខានថែទាំគ្រួសារ (អាចជាហេតុធ្វើអោយប្រពន្ធផិតក្បត់ក៏មាន ) ខូចកិត្តិយសខ្លួន និង វង្សត្រកូល មានរឿងអាស្រូវ ច្រើនមិន ចេះចប់ សុខភាពចុះថយជាលំដាប់ ប្រឈមមុខនឹងការឆ្លងជំងឺផ្សេងៗ ជាពិសេសរោគសង្គម និង កាមរោគ។

អ្នកលេងល្បែងស្រានាំមកនូវគុណវិបត្តិយ៉ាងច្រើនដូចជា វិនាសទ្រព្យសម្បត្តិដែលមានស្រាប់ ខាតពេលមិនបានរកទ្រព្យថ្មី និង ខានប្រកបការងារផ្សេងៗ មានរឿងរ៉ាវច្រើន បង្កការឈ្លោះទាស់ទែង និង អំពើហឹង្សាញឹកញាប់ និយាយស្តីគ្មានសតិ គ្មានសុជីវធម៌ បាត់បង់សីលធម៌ ខូចភាពថ្លៃថ្នូរ (អាចអោយគេមើលងាយដល់កូន ប្រពន្ធ និង វង្សត្រកូល) មិនបានថែគ្រួសារ ខ្សោយប្រាជ្ញា និង ខ្សោយសុខភាពជាលំដាប់ ។

ល្បែងភ្នាល់គ្រប់យ៉ាងក៏ធ្វើអោយស្រកស្រុតស្រយុតរបូតទ្រព្យសម្បត្តិ យ៉ាងលឿនរហូតលក់កេរមរតក និង ប្រព្រឹត្តខុសផ្សេងៗទៀត ដូចជាសំណូកសូកប៉ាន់ ពុករលួយ និង ចោរកម្មនាំអោយមានទំនាស់បែកបាក់គ្រួសារ ខូចកេរ្តិ៍ឈ្មោះ ធ្វើអោយអ្នកដទៃអស់ទំនុកចិត្ត (គេមើលងាយដល់កូនចៅ) ។ ហេតុនេះ ល្បែងស្រី ល្បែងស្រា និង ល្បែងស៊ីសង ល្បែងមួយណាក៏ជាប្រមុខនៃក្តីវិនាសទី៨ ។

## ៩- បុរសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹង ស្រីពេស្យា ទ្រូស្តនឹងប្រពន្ធកូនខ្លួនឯង

ស្រីពេស្យា គឺស្រីអ្នកប្រកបរបរផ្លូវភេទ ដោយចេញមុខ ឬ ដោយលួចលាក់ ធ្វើជាទូទៅ ឬ

មិនទូទៅ (គឺចំពោះតែបុគ្គលជាក់លាក់ ដែលមានរូបភាពជាស្រីកំណាន់ជាដើម ) មិនពិបាកយល់ទេ គឺថានាងនែបនិត្យរួមមេត្រី ដើម្បីផលប្រយោជន៍អ្វីម្យ៉ាង ហេតុនេះនាងមុខជាសំដែងឫកពារម៉ិកម៉ូក់ ខ្នក់ខ្នាញ់ ផ្គាប់ផ្គុនណាស់ ប៉ុន្តែចូរចងចាំថា នាងកំពុងមើលមកអ្នកថាជាមនុស្សមិនដឹងខ្យល់អ្វីឡើយ ហើយអ្នកនឹងត្រូវនាងអូសទាញអោយធ្វើអាក្រក់ជំនួសនាងក៏មាន ។ ចំណែកនាងជាភរិយា ដោយហេតុតែនាងត្រូវរួមដំណើរជីវិតនឹងអ្នក ទើបត្រូវនិយាយពាក្យពិតហើយពាក្យពិតវែងស្លែង ។ ជូនកាលនាងខ្វល់តែរឿងថែទាំគ្រួសារ ភ្លេចថែទាំខ្លួនឯង ធ្វើអោយរូបសម្ផស្សរបស់នាងមិនសូវផូរផង់ ប៉ុន្តែ នាងជាអ្នកគូសវាសផែនទីនៃសុភមង្គលគ្រួសារ ជាសំបុកដ៏កក់ក្តៅសម្រាប់អ្នក ។ ពេលប្តីយំ នាងជាអ្នកស្រក់ទឹកភ្នែក (ឬ ជូតទឹកភ្នែកអោយប្តី ) ពេលស្វាមីសើច នាងជាអ្នកទះដៃ ពេលស្វាមីច្រៀង នាងជាអ្នកបន្ទរ....។ អ្នកត្រេកអរនឹងស្រីពេស្យា នាំអោយអស់ទ្រព្យសម្បត្តិ ប្រាក់កាស់ និង បែកបាក់គ្រួសារ (អាចនាំអោយប្រពន្ធផិតក្បត់ក៏មាន ) សុខភាពចុះថយជាលំដាប់ ប្រឈមមុខនឹងការឆ្លងរោគច្រើនប្រការមានកាមរោគជាដើម នឹង ត្រូវគេតិះដៀល (មើលងាយដល់កូន ) ។ ហេតុនេះបុរសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជក់ចិត្ត ជាប់ជួន នឹងស្រីពេស្យា ទ្រូស្តនឹងប្រពន្ធកូនខ្លួន ជាប្រមុខនៃក្តីវិនាសទី៩ ។

## ១០- បុរសដែលមានវ័យចំណាស់ពេក ហើយមានតម្រេកដោយក្តីតណ្ហា នាំយកស្រីក្មេងធ្វើជាភរិយា

បុគ្គលដែលមានវ័យចំណាស់ចាស់ទៅហើយ យកមនុស្សវ័យក្មេងធ្វើជាភរិយា ឬ ជាស្វាមី, នៅចំពោះមុខ ប្រហែលជាមានគេសរសើរថាជាគោចាស់ប្រទះស្មៅខ្ចី ប៉ុន្តែជនជាសប្បុរស និងបណ្ឌិតទាំឡាយរមែងតិះដៀល (មនុស្សទូទៅហៅថាចាស់ព្រើល) ។ ដោយហេតុតែការងប់ងល់នឹងភរិយា (ឬស្វាមី) ក្មេងនោះ ធ្វើអោយបុគ្គល ចំណាស់នោះតែងខ្វល់ខ្វាយតែនឹងរឿងផ្គាប់ផ្គុន ទោះនាងធ្វើអ្វីខុសឆ្គង ក៏មិនហ៊ានប្រកាន់ ព្រោះខ្លាចនាងមិនសប្បាយចិត្ត នាងង៉ក់ងរម្ល៉ោះហើយចេះតែញាក់តាមមនោគតិរបស់នាង ដែលអាចអោយបុរសចំណាស់ នោះហ៊ានប្រព្រឹត្ត អកុសល និង អំពើអយសផ្សេងៗដើម្បីបំពេញចិត្តនាង ប៉ុន្តែអ្នកដទៃឆ្លងភ្នែកឃ្នើសចិត្តក្រៃពេក ។ បើបុគ្គល នេះមានកូនប្រពន្ធស្រាប់ផងនោះ កូននិងប្រពន្ធមុខជាខ្វាត់ខ្វាយ និរាសចាកសុខជាប្រាកដ។

ដោយហេតុតែរវល់នឹងរឿងផ្កាប់ផ្កូន ទើបមិនមានពេលគិតពិចារណារកធម៌អាថ៌សម្រាប់ខ្លួន ។ លុះពេលស្លាប់ទៅ យកទៅតាមខ្លួនតែបាបកម្មដោយសារផ្កាប់ចិត្តនាង ហើយស្លាប់ទាំងបិទភ្នែកមិនជិត ស្លាប់ទាំងអាឡោះអាល័យ ចំពោះភរិយាក្មេងខ្ចី ។ ប្រការនេះ មានរឿងតាជូជកជាគំរូស្រាប់ ។ ហេតុនេះ បុរសដែលមានវ័យចំណាស់ ហើយមាន តម្រេកតណ្ហា នាំយកស្រីក្មេងធ្វើជាភរិយា ជាប្រមុខនៃក្តីវិនាសទី១០ ។

## ១១- បុរសអ្នកតាំងស្រី ឬ ស្ត្រីអ្នកតាំងបុរសដែលជាអ្នកលេងខ្ជះខ្ជាយ

ការតាំងស្រី ឬ តាំងបុរសអ្នកលេងខ្ជះខ្ជាយ បានដល់ការដែលយកស្ត្រី ឬ បុរសដែលជាបុគ្គលមានចិត្តគំនិតគិតតែពីរឿងស៊ីចាយសប្បាយហ៊ឺហា មិនខ្វល់ខ្វាយ ពីរឿងសិក្សារៀនសូត្រដើម្បីចាប់យកអាជីព ឬ ប្រកបការងារក្នុងការរកនិង រក្សាទ្រព្យសម្បត្តិ មិនត្រៀមខ្លួនសម្រាប់ជីវិតនាពេលខាងមុខជាដើម មកជាគូកំណាន់ ឬ ជាគូកៀកកើយ ជាគូមេត្រី ។ ប្រការនេះ នាំអោយបុគ្គលនោះរលាយទ្រព្យសម្បត្តិ និង សមត្ថភាពដែលមានស្រាប់នោះយ៉ាងលឿន ។ មិនយូរប៉ុន្មាន គេនឹងខ្សោះអស់ទ្រព្យ ធ្លាក់ខ្លួនក្រ ហើយ ក៏មិនដឹងថា នឹងត្រូវធ្វើយ៉ាងណា ដើម្បីក្រោកឈរវិញឡើយ ។ ស្ត្រី ឬ បុរសដែលខ្លួនតាំងជាគូគាប់នោះ ប្រហែលជាងាកមកមើលងាយ បញ្ឈឺបញ្ចើចបញ្ចើដាក់បុគ្គលនោះវិញ ហើយហាក់ទៅ សប្បាយហ៊ឺហាជាមួយអ្នកផ្សេងទៀត ។ ការតាំងស្រី ឬ តាំងបុរសដែលជាអ្នកលេងខ្ជះខ្ជាយ ជាប្រមុខនៃក្តីវិនាសទី១១ ។

## ១២- ជនអ្នកកើតក្នុងត្រកូលក្សត្រ ហើយក្រខ្សត់ធនធាន មានគំនិតគិតប៉ងជាក្សត្រ

ដោយសារតែចិត្តលោភលន់នេះ បុគ្គលដែលស្ថិតនៅក្នុងខត្តិយត្រកូល (ឬត្រកូលអ្នកដឹកនាំជាតិ) ជាត្រកូលដ៏ខ្ពង់ខ្ពស់រូបនេះ បង្កើតក្រុមបក្សពួកដើម្បីដណ្តើមរាជ សម្បត្តិ (ឬ អាសនៈជាអ្នកដឹកនាំជាតិ ) ដោយហេតុតែចង់សោយសុខលើគំនរភ្នំមាស ភ្នំប្រាក់ និង ភ្នំកាមសុខផ្សេងៗ ។ បុគ្គលនេះ ចង់បានជាក្សត្រ (ជាអ្នកដឹកនាំជាតិ) នេះមិនមែន ដោយសារខ្លួនមានសមត្ថភាពដឹកនាំជាតិ ចំណែកអ្នកដឹកនាំកំពុងនៅក្នុងតំណែង ជាមនុស្សអសមត្ថភាព ឬ អ្នកអយុត្តិធម៌ជាដើមនោះទេ ការពិតគេចង់បានតំណែងនោះដោយសារតែគេចង់សោយសុខ ឬ ដោយហេតុល្មោភ ឬ ដោយភាពលង់ក្នុងការបញ្ជោររបស់អ្នកដទៃទាំងងងឹតងងល់តែប៉ុណ្ណោះ ។ ហេតុនេះ ប្រសិនបើបំណងរបស់គេបានសម្រេចមែននោះ បុគ្គល

នេះមុខជាគ្មានធ្វើអ្វីសម្រាប់ជាតិ ក្រៅតែសប្បាយហ៊ឺហា ចាយបង្ហិនបង្ហោចទ្រព្យជាតិ បំផ្លាញច្បាប់រដ្ឋ បំផ្លាញភាពរលូននៃរចនាសម្ព័ន្ធនានា បំផ្លាញភាពសាន្តត្រាណរបស់សង្គមឡើយ ។ មិនយូរប៉ុន្មាន មុខជាមានការបះបោរ ហើយនឹងនាំយកបុគ្គលនេះទៅផ្តន្ទាទោសជាមិនខាន ។ ជួនកាលបុគ្គលនេះ លុះក្នុងការល្បួងលោម បញ្ឆោតបញ្ឆោពីពួកខិលខូចក្រុមណាមួយអោយលង់ធ្វើបែបនេះ ដូចជាសរសើររឿយៗថា បុគ្គលនោះមានចារិត ឫកពា រូបរាង មុខមាត់ និង សមត្ថភាព...សក្តិសមនឹងឋានៈដ៏កំពូលនោះ ហើយថា ពេញចិត្តផ្ញើវាសនា និង សន្យាថានឹងជួយបុគ្គលនោះអោយបានជោគជ័យដោយប្រការផ្សេងៗជាដើម ។

តាមពិត បុគ្គលនោះគ្រាន់តែឧបករណ៍ នៃល្បែងដណ្តើមអំណាច ឬ ជាកម្មបទនៃការបំបែកបំបាក់សាមគ្គីភាពនៃរាជវង្ស (ឬគ្រួសារអ្នកដឹកនាំជាតិ ) តែប៉ុណ្ណោះ ។ ជាអកុសលបុគ្គលនោះ ដោយហេតុតែភាពលង់ខ្លៅ ឬ ដោយហេតុតែភាពល្មោភ ទើបមិនយល់ពីឧបាយនេះ ក៏ក្លាយទៅជាសត្វមាន់ដែលជនទុច្ចរិតចាប់បញ្ជល់ជាមួយគ្នាឯង ។ ប៉ុន្តែដោយហេតុតែភាពលង់ខ្លៅនេះ ប្រហែលជាមិនទាន់បានសម្រេចបំណងផង ក៏ត្រូវគេចាប់បញ្ចូលទ្រុង ឬនិរទេសបាត់ទៅហើយ ។

នៅក្នុងការឆ្លើយនឹងប្រស្នារបស់មនុស្ស និង ទេវតា ព្រះសម្មាសម្ពុទ្ធបានត្រាស់សំដែងថា ប្រមុខនៃក្តីវិនាស មាន១២ ប្រការយ៉ាងនេះឯង ។

---

(១) សំណាង = ការសាង គឺទង្វើដែលគេធ្វើ ឬ អ្វីដែលជាសមិទ្ធិផលនៃការសាង ដូច្នេះពាក្យថា ព្រេងសំណាង មិនមែនសំដៅលើបុណ្យពីជាតិមុនតែម្យ៉ាងឡើយ គឺមានន័យ ថា អ្វីទាំងឡាយណាដែលគេបានធ្វើហើយពីកាលមុន ដោយរួមទាំងពីអតីតជាតិ និង ក្នុងជាតិនេះ ដូចជាកាលពីខែមុន ឆ្នាំមុន ជាដើមផងដែរ ។ ឧទាហរណ៍ ចំណេះវិជ្ជាដែលយើងបានសិក្សាហើយ ក៏ចាត់ទុកជាព្រេងសំណាងមួយដែរ ។ បើបុគ្គលណានិយាយថា ពឹងលើសំណាង មានន័យថា ពឹងលើអ្វីដែលគេធ្វើ ។

---

ខឿន សាឃាង